**ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា**
**ការិយាល័យផ្នែកអប់រំកុមារមុនថ្នាក់មត្តេយ្យ**
**មជ្ឈមណ្ឌលអប់រំ**
440 NORTH BROAD STREET, **ជាន់ទី២ ច្រកចូល** C
PHILADELPHIA, PENNSYLVANIA 19130

Renee Queen Jackson
*នាយិការង*

**ទូរស័ព្ទ៖ (២១៥) ៤០០-៤២៧០**
ទូរសារ៖ (២១៥) ៤០០-៤២៧១

ជូនចំពោះមាតាបិតា/អាណាព្យាបាល៖

ដោយសារមានអំពើហឹង្សាកើតឡើងនៅតាមសាលាទូទាំងប្រទេស ក្នុងពេលថ្មីៗនេះ វាជាការចាំបាច់ដើម្បីរៀបចំជាថ្មីឲ្យមានសន្តិសុខ នៅក្នុងទីកន្លែងនៃកម្មវិធី Head Start របស់យើង។ ចាប់ផ្តើមនៅថ្ងៃច័ន្ទ ទី១ ខែមេសា ឆ្នាំ២០១៣ នឹងមានវិធីធ្វើឲ្យមានសុវត្ថិភាព នៅពេល មកដល់/ចេញពី កម្មវិធី Head Start នៅសាលា Germantown។ គេកំពុងរៀបចំវិធីនេះដើម្បីឲ្យក្មេងរបស់យើងទាំងអស់សុវត្ថិភាព។

ក្មេងនឹងតម្រង់ជួរនៅក្រោមជណ្តើរ ខាងមុខអាគារ នៅម៉ោង ៨:៣០ ព្រឹក។ បន្ទប់លេខ១ និងលេខ២ នឹងតម្រង់ជួរខាងក្រោមជណ្តើរ នៅខាងឆ្វេងទ្វារ។ បន្ទប់លេខ៣ និងលេខ៤ នឹងតម្រង់ជួរខាងក្រោមជណ្តើរ នៅខាងស្តាំទ្វារ។ ការចុះហត្ថលេខានឹងធ្វើឡើងនៅកន្លែងនេះ។ សូមរង់ចាំជាមួយកូនលោកអ្នក រហូតដល់ពេលគ្រូនាំសិស្សចូលក្នុងអាគារ។ បើកូនរបស់លោកអ្នកមកដល់ក្រោយម៉ោង ៩:០០ ព្រឹក លោកអ្នកត្រូវចូលក្នុងអាគារតាមទ្វារចូលរបស់វិទ្យាល័យ ហើយដើរកាត់អាគារ ទៅកាន់ទ្វាររបស់ កម្មវិធី Head Start។ សមាជិកបុគ្គលិកនឹងទទួលលោកអ្នកនៅមាត់ទ្វារ ជាកន្លែងដែលលោកអ្នកត្រូវចុះហត្ថលេខានៅពេលមកដល់។ សមាជិកបុគ្គលិកនឹងជូនកូនលោកអ្នកទៅកាន់បន្ទប់រៀន។

ក្មេងនឹងតម្រង់ជួរក្រោមជណ្តើរ ខាងមុខអាគារ នៅវេលាម៉ោង ៣:០០ រសៀល។ បន្ទប់លេខ១ និងលេខ២ នឹងតម្រង់ជួរក្រោមជណ្តើរ នៅខាងឆ្វេងទ្វារ។ បន្ទប់លេខ៣ និងលេខ៤ នឹងតម្រង់ជួរក្រោមជណ្តើរ នៅខាងស្តាំទ្វារ។ ការចុះហត្ថលេខាចេញនឹងធ្វើឡើងនៅក្នុងទីធ្លាសាលា។ នៅពេលហួសម៉ោងដែលត្រូវមកយកក្មេង គេនឹងនាំសិស្សានុសិស្សដែលមិនទាន់មានអ្នកណាមកយក ទៅបន្ទប់សម្រាប់អ្នកដែលមកយកក្មេងយឺតពេលនៅក្នុងអាគារ ជាមួយបុគ្គលិកសម្រាប់អ្នកមកយកក្មេងយឺតពេល។ នៅពេលអ្នកដែលគេបានចាត់តាំងឲ្យមកយកក្មេងមកដល់ បុគ្គលិកនឹងមើលបញ្ជាក់នូវអត្តសញ្ញាណប័ណ្ណ ហើយចម្លងអត្តសញ្ញាណប័ណ្ណនោះ បើសិនជាគ្មាននៅក្នុងសំណុំឯកសារ។ នៅពេលគេបានមើលបញ្ជាក់នូវអត្តសញ្ញាណប័ណ្ណរួចហើយ គេនឹងឲ្យកូនរបស់លោកអ្នកទៅអ្នកមកយកក្មេង។ សូមធ្វើយ៉ាងណាឲ្យអ្នកមកយកកូនរបស់លោកអ្នកមានព័ត៌មានថ្មីៗនៅក្នុងបញ្ជី។

សូមប្រាប់ឲ្យគ្រូដឹងនៅពេលព្រឹក បើសិនជាត្រូវការឲ្យកូនចេញមុនម៉ោង នៅថ្ងៃរសៀល។ ពេលមកយកកូនរបស់លោកអ្នក នៅពេលចេញមុនម៉ោង គេនឹងសុំឲ្យលោកអ្នកបញ្ជាក់ខ្លួននៅត្រង់ទ្វារចូល ប្រាប់ឈ្មោះកូន និងលេខបន្ទប់។ សមាជិកបុគ្គលិកនឹងនាំកូនលោកអ្នកទៅកាន់ទ្វារដើម្បីឲ្យចេញ។

គោលបំណងនៃច្បាប់នេះ គឺធ្វើឲ្យអាគារមាន សន្តិសុខ និងសុវត្ថិភាព និងសុវត្ថិភាពដល់ក្មេងទាំងអស់ក្នុងកម្មវិធី Head Start នៅសាលា Germantown។ សូមអរគុណចំពោះការសហការរបស់លោកអ្នកជាមួយច្បាប់ថ្មីនេះ។ ខ្ញុំសង្ឃឹមថា ក្រៅពីធ្វើឲ្យកូនលោកអ្នកមានសុវត្ថិភាព ច្បាប់នេះក៏ធ្វើឲ្យក្រុមគ្រួសាររបស់យើងគ្មានការភ័យព្រួយ ដោយដឹងថាការចូលក្នុងអាគារមានសុវត្ថិភាព។

បើសិនជាលោកអ្នកមានសំណួរអ្វី អាចទូរស័ព្ទមកនាងខ្ញុំលេខ ២១៥-៤០០-៥៥៣២។

សូមអរគុណ

Sandra Snyder
អ្នករៀបចំផ្នែកអប់រំ តំបន់៤